**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អ្នកនាំពាក្យ គ.ជ.ប**

**លេខ ០៥៩ គ.ជ.ប**

ថ្ងៃពុធ ១៤រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## ការផ្តល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩

បន្ទាប់ពីបានបញ្ចប់ការបិទផ្សាយបញ្ជីបោះឆ្នោតជំបូង ការដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងជំទាស់ចប់រួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ស្តីពីការផ្តល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩ ចំនួនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងចំនួនការិយាល័យបោះឆ្នោត ក្រោមអធិបតីភាពឯកឧត្តម **នុត សុខុម** អនុប្រធាន គ.ជ.ប និងជាប្រធានដឹកនាំអង្គប្រជុំ នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ នៅទីស្តីការ គ.ជ.ប ។

ភាគីពាក់ព័ន្ធដែលចូលរួមកិច្ចប្រជុំនេះ រួមមាន៖ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន តំណាងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១១ តំណាងគណបក្សនយោបាយចំនួន ១០ អង្គភាពសារព័ត៌មានចំនួន ១៣ និងមន្ត្រី គ.ជ.ប ចំនួន ២០ នាក់ សរុបចំនួន ៨០នាក់។

ឯកឧត្តម **នុត សុខុម** បានមានប្រសាសន៍ថា គ.ជ.ប សម្រេចផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩ ដូចខាងក្រោម៖

- ប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោតថ្មីចំនួន **១០៨,២៧២** នាក់
- ឈ្មោះដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោតចំនួន **៩២,៩១៧** នាក់
- ប្រជាពលរដ្ឋផ្ទេរចូលចំនួន **១៩,១១៧** នាក់
- ប្រជាពលរដ្ឋសរុបដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ ២០១៩ ចំនួន **៨,៦២៩,៣៥៧** នាក់ ស្មើនឹង **៨៩.៧៨%** ធៀបនឹងចំនួនប្រជាពលរដ្ឋប៉ាន់ស្មានសរុបដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ។

សម្រាប់ការិយាល័យបោះឆ្នោតវិញ ឯកឧត្តមបានបញ្ជាក់ថា មាន ២៣,៣៦៥ ការិយាល័យក្នុងឆ្នាំ២០១៩ www.necelect.org.kh/khmer/content/4133 ។

នៅក្នុងឱកាសនេះដែរក៏មានតំណាងអង្គការនិកហ្វិច អង្គការខុមហ្វ្រែល និងតំណាងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានសំណូមពរដល់ គ.ជ.ប ទាក់ទងទៅនឹងការអប់រំផ្សព្វផ្សាយដល់យុវជននៅតាមសាលារៀន និងនៅតាមរោងចក្រសហគ្រាស ដើម្បីឱ្យចាប់អារម្មណ៍ដល់ការចុះឈ្មោះបោះឆ្នោត ដែល គ.ជ.ប ត្រូវធ្វើជាប្រចាំឆ្នាំ។

ឆ្លើយតបនឹងសំណូមពរនេះ ឯកឧត្តមប្រធានដឹកនាំអង្គប្រជុំបានលើកឡើងថា ការងារនេះ គ.ជ.ប ធ្លាប់បានធ្វើរួចមកហើយ ដោយឯកឧត្តមប្រធាន គ.ជ.ប បានចុះអប់រំផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងដល់ក្រុមយុវជននៅតាមភូមិភាគទាំង ៥ ហើយទទួលបានជោគជ័យយ៉ាងខ្លាំង។ ជាមួយគ្នានេះ គ.ជ.ប ក៏មានគម្រោងសម្រាប់ឆ្នាំ ២០២០ ខាងមុខ ដោយសហការជាមួយម្ចាស់ជំនួយ អាចនឹងធ្វើដូចខាងក្រោម៖

- ផ្សព្វផ្សាយដោយផ្ទាល់នៅតាមសាលារៀន
- ដាក់កម្មវិធីអប់រំនៅលើគេហទំព័រ
- ស្នើទៅក្រសួងអប់រំដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សា

ចំពោះការងារអប់រំផ្សព្វផ្សាយនៅតាមរោងចក្រសហគ្រាសវិញ គ.ជ.ប នឹងយកទៅពិចារណា។ ប៉ុន្តែអ្វីដែល គ.ជ.ប បាននិងកំពុងធ្វើ ហើយក៏ធ្លាប់បានធ្វើរួចមកហើយ គឺផ្តល់បាឋកថានៅច្រើនកន្លែងតាមការស្នើសុំរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ចំណុចនេះ គ.ជ.ប នៅតែត្រៀមខ្លួនរួចជាស្រេចដើម្បីបន្តកិច្ចសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ហើយ គ.ជ.ប ក៏ស្នើសុំទៅកាន់ភាគីពាក់ព័ន្ធទាំងអស់ថាការងារអប់រំប្រជាពលរដ្ឋពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតនេះ គឺអាចធ្វើជារួមបាន មានន័យថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសហការរៀបចំរួមគ្នា ដោយ គ.ជ.ប ជាអ្នកផ្តល់វាគ្មិន និងត្រៀមឯកសារអប់រំផ្សព្វផ្សាយ។

សូមជម្រាបជូនថា បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ ២០១៩ គ.ជ.ប នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ហើយបញ្ជីបោះឆ្នោតផ្លូវការនេះ គ.ជ.ប នឹងបញ្ជូនទៅរក្សាទុកជាឯកសារនៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងនៅតាមសាលាឃុំ សង្កាត់ ទាំង ១,៦៤៦ ទូទាំងប្រទេស។

ខ្លឹមសារផ្សព្វផ្សាយរបស់ឯកឧត្តម **នុត សុខុម** អនុប្រធាន គ.ជ.ប មានផ្សព្វផ្សាយនៅលើគេហទំព័រ គ.ជ.ប www.necelect.org.kh/khmer/content/4134 ៕

**ចំពោះព័ត៌មានពិស្តារ សូមទាក់ទង!**


| | |
|---|---|
| ឯកឧត្តម **ហង្ស ពុទ្ធា** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 959 666<br>Email : hangputhea@gmail.com | ឯកឧត្តម **ឌីម សុវណ្ណារុំ** សមាជិក និងជាអ្នកនាំពាក្យ គ.ជ.ប<br>Tel: (855)12 518 485<br>Email : sovannaromhy@yahoo.fr |